ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ...១៩...សសរ

# សារលិខិត

## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសខួបលើកទី៦៩ ទិវាកុមារអន្តរជាតិ ១ មិថុនា ខួបលើកទី១៧ ទិវាពិភពលោកប្រឆាំងពលកម្មកុមារ ១២ មិថុនា និងទិវាកុមារកម្ពុជា ឆ្នាំ២០១៨

- *សូមថ្វាយបង្គំសម្តេចព្រះមហាសង្ឃរាជទាំងពីរគណៈ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ*
- *សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី*
- *បងប្អូនជនរួមជាតិ និងក្មួយៗកុមារា កុមារីជាទីស្រឡាញ់ ។*

ក្នុងឱកាសដ៏មហោឡារិកនៃ**ខួបលើកទី៦៩ ទិវាកុមារអន្តរជាតិ ១ មិថុនា ខួបលើកទី១៧ ទិវាពិភពលោកប្រឆាំងពលកម្មកុមារ ១២ មិថុនា និងទិវាកុមារកម្ពុជា ឆ្នាំ២០១៨** នេះ ទូលព្រះបង្គំ ខ្ញុំព្រះករុណាខ្ញុំ ក្នុងនាមរាជរដ្ឋាភិបាល និងក្នុងនាមប្រធានកិត្តិយសក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ សូមសម្តែងនូវមនោសញ្ចេតនារីករាយ និងគាំទ្រយ៉ាងពេញទំហឹងចំពោះការរៀបចំទិវាដ៏មានសារៈសំខាន់នេះ។ ការប្រារព្ធទិវាដ៏មានអត្ថន័យនេះគឺបង្ហាញអំពីឆន្ទៈមោះមុត និងការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលក្នុងការបន្តលើកកម្ពស់ការអនុវត្តសិទ្ធិកុមារ និងសូមលើកទឹកចិត្តឱ្យបងប្អូនជនរួមជាតិយើងទាំងអស់ រួមគ្នាបន្តលើកស្ទួយវិស័យសុខមាលភាពកុមារឲ្យកាន់តែល្អប្រសើរ ដើម្បីឧត្តមប្រយោជន៍របស់កុមារនៅកម្ពុជា។

ឆ្នាំនេះ ទិវាកុមារកម្ពុជា និងទិវាកុមារអន្តរជាតិ ១ មិថុនា ត្រូវបានប្រារព្ធឡើងក្រោមប្រធានបទ "**រួមគ្នាការពារកុមារ ដើម្បីអភិវឌ្ឍគ្រួសារនិងសង្គមជាតិ**" និងទិវាពិភពលោកប្រឆាំងពលកម្មកុមារ ១២ មិថុនា ក្រោមប្រធានបទ "**ទប់ស្កាត់គ្រោះថ្នាក់ការងារ និងភាពងាយរងគ្រោះផ្នែកសុខភាពសម្រាប់កម្មករនិយោជិតវ័យក្មេង ដើម្បីលុបបំបាត់ពលកម្មកុមារ**" ដើម្បីលើកដល់សិទ្ធិជាមូលដ្ឋានរបស់កុមារ និងបង្ហាញពីការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាល ក្នុងការដោះស្រាយបញ្ហាប្រឈមទាំងឡាយរបស់កុមារ ជាពិសេស ការពារកុមារពីការរំលោភបំពាន ពលកម្មកុមារគ្រប់ទម្រង់ ជួយគាំទ្រដល់កុមាររងគ្រោះ និងងាយរងគ្រោះបានទាន់ពេលវេលាប្រកបដោយសុវត្ថិភាព និងមានប្រសិទ្ធភាព ព្រមទាំងរស់នៅយ៉ាងសុខដុមរមនាជាមួយគ្រួសារនៅក្នុងសង្គមដែលពោរពេញទៅដោយសន្តិភាព។

ព្រះរាជាណាចក្រកម្ពុជាកំពុងរក្សាបាននូវស្ថិរភាពនយោបាយ សុខសន្តិភាព និងសណ្តាប់ធ្នាប់សាធារណៈយ៉ាងល្អប្រសើរទូទាំងប្រទេស ដែលកត្តានេះបានបង្កលក្ខណៈងាយស្រួលដល់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍសង្គមជាតិ ដើម្បីគោលដៅកសាងអនាគតកម្ពុជាមួយដ៏រុងរឿង ឆ្លើយតបនឹងបំណងប្រាថ្នារបស់ប្រជាជនគ្រប់វ័យ

និងគ្រប់ស្រទាប់វណ្ណៈ។ ជាមួយនឹងប្រធានបទដែលបានលើកឡើងខាងលើ ទិវាដ៏មានសារៈសំខាន់នេះ បានជំរុញឲ្យយើងត្រូវខិតខំឲ្យបានខ្លាំងក្លាថែមទៀត លើការអនុវត្តសិទ្ធិចម្បងទាំងបួនរបស់កុមារឲ្យមានប្រសិទ្ធភាព ក្នុងនោះសិទ្ធិទទួលបានការការពារគឺជាសិទ្ធិអាទិភាពចម្បងមួយ ដើម្បីការពារកុមារឲ្យរួចផុតពីហានិភ័យផ្សេងៗ ដូចជា ការរើសអើង ការរំលោភបំពាន ការកេងប្រវ័ញ្ច ការមិនយកចិត្តទុកដាក់ចំពោះកុមារដែលគ្មានគ្រួសារសាច់ញាតិ និងកុមារជាជនចំណាកស្រុកជាដើម។

កុមារគឺជាធនធានមនុស្សដែលមិនអាចខ្វះបានសម្រាប់អភិវឌ្ឍប្រទេសជាតិនាពេលអនាគត។ ដើម្បីឱ្យធនធានមនុស្សប្រកបដោយសក្តានុពល ការផ្តល់ការការពារ និងអភិវឌ្ឍកុមារ គឺជាភារកិច្ចយ៉ាងសំខាន់ដែលតម្រូវឲ្យមានការអនុវត្តតាមបែបពហុវិស័យបញ្ចូលគ្នា ហើយសកម្មភាពអាទិភាពទាំងឡាយដែលត្រូវអនុវត្តរួមមាន ការងាររៀបចំក្របខណ្ឌគតិយុត្ត ការកែលម្អយន្តការពិនិត្យតាមដាន និងវាយតម្លៃការអភិវឌ្ឍសមត្ថភាព ការពង្រីកសេវាអប់រំ ការការពារ និងថែទាំសុខភាពដល់កុមារ ការផ្តល់ការអប់រំមូលដ្ឋានឲ្យបានទាន់ពេលវេលាដល់កុមារ ដោយផ្តោតជាពិសេសលើកុមាររងគ្រោះ កុមារងាយរងគ្រោះ និងកុមារដែលមានជីវភាពក្រីក្រ។

ឆ្នាំនេះ ទិវាពិភពលោកប្រឆាំងពលកម្មកុមារផ្តោតការយកចិត្តទុកដាក់លើសុវត្ថិភាពនៅកន្លែងការងារ សុខភាពរបស់កម្មករវ័យក្មេង និងបញ្ចប់ពលកម្មកុមារ។ ទិវាដ៏សំខាន់នេះនឹងជម្រុញអោយមានការពន្លឿនសកម្មភាពដើម្បីសម្រេចបានគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ស្តីពីបរិយាកាសការងារដែលមានសុវត្ថិភាព និងសន្តិសុខសម្រាប់កម្មករទាំងអស់ត្រឹមឆ្នាំ២០៣០ និងគោលដៅស្តីពីការបញ្ចប់រាល់ទម្រង់ទាំងអស់នៃពលកម្មកុមារត្រឹមឆ្នាំ២០២៥។ ការសម្រេចបានគោលដៅខាងលើនេះ តម្រូវឲ្យមានវិធីសាស្ត្រដោះស្រាយដែលមានលក្ខណៈរឹងមាំ និងរួមបញ្ចូលគ្នាក្នុងការលុបបំបាត់ពលកម្មកុមារ និងលើកកម្ពស់វប្បធម៌នៃការបង្ការសុខភាព សុវត្ថិភាពការងារ។

កុមារមានសិទ្ធិទទួលបានការការពារពីគ្រប់ទម្រង់ទាំងអស់នៃពលកម្មកុមារ រួមទាំងការងារប្រកបដោយគ្រោះថ្នាក់ដែលបានប៉ះពាល់ដល់កុមារ។ ការប្រារព្ធទិវាពិភពលោកប្រឆាំងពលកម្មកុមារ បង្ហាញឲ្យឃើញពីសារៈសំខាន់យ៉ាងខ្លាំងនៃការធ្វើឲ្យប្រសើរឡើងនូវសុវត្ថិភាព និងសុខភាពសម្រាប់កម្មករវ័យក្មេង ប្រយុទ្ធប្រឆាំងនឹងការងារប្រកបដោយគ្រោះថ្នាក់ លុបបំបាត់រាល់ទម្រង់ទាំងអស់នៃពលកម្មកុមារ។ ជាមួយគ្នានេះ ការដកហូតកុមារដែលមានអាយុតិចជាងអាយុអប្បបរមាសម្រាប់ធ្វើការងារពីគ្រប់ទម្រង់ទាំងអស់នៃពលកម្មកុមារ រួមទាំងការងារប្រកបដោយគ្រោះថ្នាក់គឺជាសកម្មភាពចំបងដែលត្រូវអនុវត្តយ៉ាងសកម្ម។ ជាមួយនេះដែរក៏ត្រូវធានាថាកុមារទាំងនោះមានលទ្ធភាពទទួលបានការការពារ ការថែទាំ ការអប់រំប្រកបដោយគុណភាព រហូតដល់អាយុស្របច្បាប់អប្បបរមាសម្រាប់ធ្វើការងារ។

កុមារត្រូវការចាំបាច់នូវការអភិវឌ្ឍផ្នែករាងកាយ បញ្ញា ស្មារតី និងការសិក្សាអប់រំរៀនសូត្រ ហេតុនេះកុមារត្រូវការការថែទាំ ការជួយទំនុកបម្រុងពីគ្រួសារ និងសង្គម ជាពិសេសការលើកកម្ពស់កិច្ចការពារកុមារដោយឲ្យកុមារទទួលបានការសិក្សាអប់រំ ដើម្បីអភិវឌ្ឍខ្លួនប្រកបដោយសមត្ថភាពដែលអាចកសាងគ្រួសារប្រកបដោយសុភមង្គល និងរស់នៅដោយសេចក្តីថ្លៃថ្នូរ ព្រមទាំងបានចូលរួមចំណែកយ៉ាងសកម្មនិងពេញលេញក្នុងការអភិវឌ្ឍប្រទេសជាតិរបស់ខ្លួន។ បច្ចុប្បន្ន រាជរដ្ឋាភិបាលបានវិភាជធនធានបន្ថែមទៀត លើវិស័យសុខាភិបាល អប់រំ សង្គមកិច្ច និងវិស័យផ្សេងៗដែលទាក់ទងនឹងការអភិវឌ្ឍធនធានមនុស្ស ពិសេសផ្តោតលើការអភិវឌ្ឍសុខុមាលភាពកុមារ សំដៅសម្រេចឱ្យបានគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (២០១៥-២០៣០)។ ការវិនិយោគជាមួយកុមារគឺជាការងារអាទិភាព ការវិនិយោគលើកុមារនៅថ្ងៃនេះនឹងបង្កើតបានជាធនធានមនុស្សដែលមានជំនាញ និងប្រកបដោយសក្តានុពលនាពេលអនាគត ដើម្បីធានាចីរភាពកំណើនសេដ្ឋកិច្ច និងលើកកម្ពស់សុខុមាលភាពរបស់ប្រជាជន។

កិច្ចការពារកុមារគឺជាការងារពហុវិស័យដែលតម្រូវឱ្យអ្នកពាក់ព័ន្ធទាំងអស់យកចិត្តទុកដាក់ចូលរួមចំណែកអនុវត្តដោយការទទួលខុសត្រូវខ្ពស់ តាមជំនាញរៀងៗខ្លួន លើការងារការលើកកម្ពស់គុណភាពអប់រំនិងបណ្តុះបណ្តាលជំនាញ លើកកម្ពស់សុខុមាលភាពសង្គមសម្រាប់កុមារ ពង្រឹងកិច្ចការពារនិងបង្ការទប់ស្កាត់កុមារពីអំពើ

ហិរញ្ញវត្ថុនិងការងារប្រកបដោយគ្រោះថ្នាក់ ពង្រឹងកិច្ចសហប្រតិបត្តិការ ការអនុវត្តច្បាប់ ក្របខណ្ឌគតិយុត្ត និងគោលនយោបាយ រួមទាំងការពង្រឹងយន្តការជាដើម។ តាមរយៈកិច្ចខិតខំប្រឹងប្រែងនេះបានធ្វើឲ្យស្ថានភាពសិទ្ធិកុមារកាន់តែមានភាពល្អប្រសើរជាលំដាប់ ដូចជាអត្រាមរណភាពរបស់កុមារបានថយចុះជាលំដាប់ ការចុះឈ្មោះចូលរៀនមានការកើនឡើង ការជួយសង្គ្រោះកុមារពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ ដើម្បីឲ្យកុមារទទួលបានការអប់រំនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ធ្វើសមាហរណកម្មទៅក្នុងសង្គម និងការលើកកម្ពស់ការងារសមធម៌ និងសុវត្ថិភាពកុមារ។ ម្យ៉ាងទៀត កុមារមកពីគ្រួសារក្រីក្រ កុមារជនជាតិដើមភាគតិច កុមារពិការ ត្រូវបានយកចិត្តទុកដាក់គ្មានការរើសអើង មានឱកាសទទួលបានការអប់រំរៀនសូត្រ និងទទួលបានសេវាជាមូលដ្ឋានដូចៗគ្នា។

ម្យ៉ាងវិញទៀត ដើម្បីឲ្យការអនុវត្តការងារកាន់តែមានប្រសិទ្ធភាពខ្ពស់ ក្រុមការងារដែលដឹកនាំដោយកុមារជាច្រើនត្រូវបានបង្កើតឡើងដូចជា ចលនាយុវជនកាកបាទក្រហមកម្ពុជា កាយរឹទ្ធិកម្ពុជា ក្លឹបកុមារនៅតាមសាលារៀន បណ្ដាញកុមារអ្នកតស៊ូមតិ និងចលនាកុមារនិងយុវជនកម្ពុជាដើម្បីសិទ្ធិកុមារ ដែលពួកគេក្លាយជាចលនាយុវជន ឬកុមារឈានមុខក្នុងការកសាង និងអភិវឌ្ឍន៍សង្គម។ ជាមួយគ្នានេះដែរ កុមារត្រូវបានផ្ដល់នូវឱកាសក្នុងការអនុវត្តសិទ្ធិរបស់ពួកគេ ក្នុងការចូលរួមក្នុងវេទិកានៅគ្រប់កម្រិត ទាំងថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ ថ្នាក់តំបន់និងអន្តរជាតិ។ ពលមតិយោបល់របស់កុមារត្រូវបានយកមកពិចារណា និងដាក់បញ្ចូលទៅក្នុងផែនការសកម្មភាពនានាសម្រាប់អភិវឌ្ឍន៍សិទ្ធិកុមារ។ ការជំរុញឲ្យកុមារបានចូលរួមក្នុងសកម្មភាពនានាមានន័យថា ការដោះស្រាយបញ្ហារបស់ពួកគេកាន់តែមានប្រសិទ្ធភាពខ្ពស់ ព្រោះមានតែកុមារទេដែលដឹងពីស្ថានភាពតម្រូវការ និងបញ្ហារបស់គេច្បាស់លាស់។

សមិទ្ធផលដ៏ធំធេងទាំងនេះសបញ្ជាក់ពីការប្ដេជ្ញាចិត្តដ៏មុតមាំរបស់រាជរដ្ឋាភិបាល ក្នុងការលើកស្ទួយវិស័យសុខុមាលភាពកុមារ ដែលធានាឲ្យកុមារគ្រប់រូបទទួលបាននូវការគាំទ្រសម្រាប់ការចាប់ផ្ដើមជីវិតដ៏ល្អ និងអភិវឌ្ឍន៍ពោរពេញទៅដោយសក្ដានុពល ក្លាយជាពលរដ្ឋកម្ពុជាដែលមានការទទួលខុសត្រូវក្នុងគ្រួសារ និងសង្គម និងមានផលិតភាពពេញលេញមួយជីវិត។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំព្រះបង្គំ ខ្ញុំព្រះករុណាខ្ញុំ សូមកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ និងមន្ត្រីរាជការទាំងអស់នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា កាកបាទក្រហមកម្ពុជា ក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការមិនមែនរដ្ឋាភិបាលជាតិ-អន្តរជាតិ ដៃគូអភិវឌ្ឍ វិស័យឯកជន មាតាបិតា អាណាព្យាបាល លោកគ្រូ អ្នកគ្រូ និងអ្នកថែទាំកុមារទាំងអស់ ដែលបានចំណាយទាំងកម្លាំងកាយចិត្ត ប្រាជ្ញា ស្មារតី ធនធាន ប្រកបដោយការទទួលខុសត្រូវខ្ពស់ រួមចំណែកក្នុងការលើកកម្ពស់សុខុមាលភាពប្រជាពលរដ្ឋ ពិសេសចូលរួមចំណែកយ៉ាងសកម្មលើវិស័យកុមារ សំដៅធ្វើឲ្យសម្រេចបាននូវសិទ្ធិជាមូលដ្ឋានទាំងបួនរបស់កុមារ គឺសិទ្ធិរស់រានមានជីវិត សិទ្ធិអភិវឌ្ឍន៍ សិទ្ធិទទួលបាននូវការការពារ និងសិទ្ធិចូលរួមក្នុងបុព្វហេតុបង្កើតធនធានមនុស្សប្រកបដោយចំណេះដឹង ជំនាញ វិជ្ជាជីវៈ ព្រមទាំងសមត្ថភាពខ្ពស់ក្នុងការប្រកបមុខរបរ ការងារ កសាងជីវភាពគ្រួសាររស់នៅដោយសេចក្ដីថ្លៃថ្នូរ និងមានឆន្ទៈមោះមុតចូលរួមចំណែកក្នុងការអភិវឌ្ឍប្រទេសនាពេលអនាគត។

ក្នុងស្មារតីនេះ ដើម្បីរួមចំណែកគាំទ្រខួបលើកទី៦៩ ទិវាកុមារអន្តរជាតិ ១ មិថុនា ខួបលើកទី១៧ ទិវាពិភពលោកប្រឆាំងពលកម្មកុមារ ១២ មិថុនា និងទិវាកុមារកម្ពុជា ឆ្នាំ២០១៨ ខ្ញុំព្រះបង្គំ ខ្ញុំព្រះករុណាខ្ញុំ សូមធ្វើការអំពាវនាវដូចតទៅ៖

១. ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារត្រូវបន្តដឹកនាំចាត់ចែងអនុវត្តអនុសញ្ញាស្ដីពីសិទ្ធិកុមារ និងពង្រឹងការអនុវត្តលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការការពារកុមារជាមួយក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍ សង្គមស៊ីវិលប្រកបដោយប្រសិទ្ធភាព ព្រមទាំងកសាងនូវលិខិតបទដ្ឋានគតិយុត្តបន្ថែម ដើម្បីឲ្យប្រព័ន្ធកិច្ចការពារកុមារមានលក្ខណៈគ្រប់ជ្រុងជ្រោយ។

២. ក្រសួង ស្ថាប័ន អាជ្ញាធរមូលដ្ឋាន សហគមន៍ និងពលរដ្ឋគ្រប់រូបត្រូវចូលរួមអនុវត្តគោលនយោបាយ

កុមារយុំមានសុវត្ថិភាព ពិសេសចាត់វិធានការការពារកុមារពីអំពើហិង្សាគ្រប់រូបភាព អប់រំកុមារពីរបៀបការពារខ្លួនប្រឆាំងនឹងការរំលោភបំពាន ការសម្លុតគំរាមកំហែងគ្រប់បែបយ៉ាង និងត្រូវធ្វើឲ្យកុមារអាចយល់ដឹងពីវិធីរាយការណ៍ដល់អាជ្ញាធរ ឬ មនុស្សពេញវ័យដែលជាអ្នកថែទាំពួកគេ អំពីការរំលោភបំពានដល់ពួកគេតាមគ្រប់រូបភាព។

៣. ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវបន្តលើកកម្ពស់ការយល់ដឹង និងផ្សព្វផ្សាយអំពីការទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារនៅគ្រប់សកម្មភាពសេដ្ឋកិច្ច និងពង្រឹងវិធានការអធិការកិច្ចពលកម្មកុមារ ព្រមទាំងស្វែងរកដំណោះស្រាយសមស្រប ដើម្បីជួយសង្គ្រោះពលកម្មកុមារ។

៤. ក្រសួង ស្ថាប័នពាក់ព័ន្ធ ព្រមទាំងអាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ ត្រូវយកចិត្តទុកដាក់ជំរុញកុមារដែលមិនបានរៀនសូត្រ ឬបោះបង់ការសិក្សាឲ្យមានឱកាសទទួលបានការអប់រំរៀនសូត្រតាមគ្រប់រូបភាព ពិសេស ត្រូវខិតខំបង្កលក្ខណៈងាយស្រួលដល់កុមារដែលជាជនពិការឲ្យទទួលបានលទ្ធភាពក្នុងការសិក្សា។

៥. បង្កើនការយល់ដឹងដល់ប្រជាពលរដ្ឋក្នុងការកំណត់អត្តសញ្ញាណអំពើរំលោភបំពានលើកុមារ និងការលើកកម្ពស់ការយល់ដឹងចំពោះផលប៉ះពាល់អវិជ្ជមាននៃអំពើរំលោភបំពាន និងផ្តល់ភាពក្លាហានដល់កុមារនិងគ្រួសារក្នុងការរាយការណ៍អំពីការរំលោភបំពាននានា។

៦. គ្រប់ស្ថានីយវិទ្យុ និងទូរទស្សន៍របស់រដ្ឋ និងឯកជន ព្រមទាំងប្រព័ន្ធផ្សព្វផ្សាយនានា សូមបន្តជួយផ្សព្វផ្សាយឲ្យបានទូលំទូលាយអំពីការយកចិត្តទុកដាក់លើកស្ទួយវិស័យសុខុមាលភាពកុមារនៅកម្ពុជា ជាពិសេសពង្រឹងគុណភាពនៃការផលិតកម្មវិធីសម្រាប់កុមារប្រកបដោយខ្លឹមសារអប់រំ ដើម្បីបង្ការទប់ស្កាត់កុំឲ្យកុមារក្លាយជាជនរងគ្រោះ។

៧. បង្កើនកិច្ចសហប្រតិបត្តិការរវាងក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ដៃគូអភិវឌ្ឍ អង្គការមិនមែនរដ្ឋាភិបាលជាតិ-អន្តរជាតិ ដើម្បីលើកកម្ពស់សេវានានារបស់កុមារដោយបន្តបង្កើនការវិនិយោគលើកុមារដែលជាតម្រូវការចាំបាច់បំផុតរបស់មនុស្ស។

ជាទីបញ្ចប់ ទូលព្រះបង្គំ ខ្ញុំព្រះករុណាខ្ញុំ សូមថ្វាយព្រះពរសម្តេចព្រះមហាសង្ឃរាជទាំងពីរគណៈ ប្រគេនពរព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ និងជូនពរចំពោះសម្តេច ឯកឧត្តម លោកជំទាវ ជនរួមជាតិ ជាពិសេស លោកគ្រូ អ្នកគ្រូ ក្មួយៗជាទីស្រឡាញ់ទាំងអស់ សូមប្រកបដោយពុទ្ធពរទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

*ថ្ងៃព្រហស្បតិ៍ ១០កើត ខែ ចេត្រ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២*

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មេសា ឆ្នាំ២០១៩*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**